# ការទទួលខុសត្រូវលើបទល្មើស

*-ពុំទាន់មានមូលដ្ឋានគ្រប់គ្រងដើម្បីកំណត់អង្គហេតុនៃបទល្មើសនិងធាតុផ្សំនៃបទល្មើសលើជនជាប់ចោទម្នាក់ៗអោយបានច្បាប់លាស់ទេ។ ទាំងសាលាដំបូង ទាំងសាលាឧទ្ធរណ៍ ក្នុងការយល់ឃើញពុំឃើញមានបង្ហាញនូវអង្គហេតុស្ថាពរ ដែលកំណត់ថាជនត្រូវចោទម្នាក់ៗ មានសកម្មភាពយ៉ាងដូចម្ដេចនៅក្នុងបទល្មើសនេះឡើយ ដូច្នេះសាលដីការបស់សាលាឧទ្ធរណ៍នេះ មានកំហុសរំលោភទៅលើមាត្រា ៤១៩នៃក្រមនីតិវិធីព្រហ្មទណ្ឌ* (សាលដីកាតុលាការកំពូលលេខ២៤៤, ២០១៣, ទំ.៧)។

**កំណត់សំគាល់៖ ក.** ដើម្បីឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ វាទាមទារនូវការបង្ហាញថាបទល្មើសត្រូវបានប្រព្រឹត្ត (ធាតុផ្សំសំភារៈនិងអត្តនោម័ត) និងការចូលរួមរបស់បុគ្គលម្នាក់ៗ ដូចជាការបញ្ជា ការប្រព្រឹត្ត (commission) ការជួយ (aiding)។ **ខ.** តុលាការកំពូល អះអាងអំពីអង្គហេតុស្ថាពរ និងទាមទារឲ្យមានការកំណត់អង្គហេតុសន្និដ្ឋាននៃបទល្មើស។ បន្ថែមពីលើនេះ វាទាមទារឲ្យមានការបង្ហាញច្បាស់លាស់ការចូលរួមរបស់ជនល្មើសម្នាក់ ចូលរួមដូចម្ដេចក្នុងបទល្មើស។

## មាត្រា៤១៩មូលហេតុនៃបណ្ដឹងសាទុក្ខ

តុលាការកំពូលអាចបដិសេធសេចក្ដីសម្រេចក្នុងករណីដូចតទៅ ៖

- សមាសភាពមិនស្របច្បាប់នៃតុលាការ - អសមត្ថកិច្ចនៃតុលាការ - ការរំលោភអំណាច -ការបំពានច្បាប់ឬការអនុវត្តខុសច្បាប់ - ការបំពានឬភ្លេចទម្រង់ការដែលច្បាប់បញ្ញត្តិថាត្រូវទុកជាមោឃៈ -ការមិនបានសម្រេចលើពាក្យប្ដឹងសុំរបស់អយ្យការ ឬភាគីកាលណាពាក្យប្ដឹងសុំនេះធ្វើជាលាយលក្ខណ៍អក្សរ និងមានន័យយ៉ាងច្បាស់លាស់ - ការបំភ្លៃអង្គហេតុ- គ្មានសំអាងហេតុ- ការផ្ទុយគ្នារវាងសំអាងហេតុ និងសេចក្ដីសម្រេច ។

សម្រាប់សាលក្រមនិងសាលដីកាពាក់ព័ន្ធសូមចុចលើតំណភ្ជាប់នេះ។